

ចូរទុកដាក់ផ្លូវរបស់អ្នកនឹងព្រះយេហូវ៉ាចុះ ថែមទាំងទុកចិត្តដល់ទ្រង់ផង



(2)

នេះគឺជាពាក្យរបស់លោក ដេ រិក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> ចូរទុកដាក់ផ្លូវអ្នកនឹងព្រះយេហូវ៉ាចុះ
> ថែមទាំងទុកចិត្តដល់ទ្រង់ផង
> នោះទ្រង់នឹងប្រោសឲ្យបានសម្រេច។ [ទំនុកតម្កើង ៣៧:៥]

តើអ្នកចង់ឲ្យព្រះជាម្ចាស់គ្រប់គ្រងស្ថានភាពរបស់អ្នក ជីវិតរបស់អ្នក បញ្ហារបស់អ្នកឬទេ? មានជំហានដ៏សាមញ្ញចំនួនបី ត្រូវបានចង្អុលបង្ហាញនៅក្នុងព្រះបន្ទូលដែលខ្ញុំទើបតែបានអានជូនលោកអ្នក។

ជំហានដំបូង៖ ត្រូវតែទុកដាក់ផ្លូវអ្នកនឹងព្រះយេហូវ៉ា។
នេះគឺជាកិច្ចការតែម្តងគត់ ជាសកម្មភាពដែលមានការសម្រេចចិត្ត។
អ្នកគ្រាន់តែទុកដាក់ផ្លូវអ្នកនឹងព្រះយេហូវ៉ា
អ្នកត្រូវតែលែងវាចេញពីដៃរបស់អ្នក។
វាដូចជាការយកលុយរបស់អ្នកទៅធនាគារ និងដាក់វា
ហើយទទួលយកវិក្កយបត្រសម្រាប់ការដាក់វា។

ជំហានបន្ទាប់៖ ថែមទាំងទុកចិត្តដល់ទ្រង់ផង។
ការទុកចិត្តគឺជាឥរិយាបថធ្វើជាបន្តនៅជាប់ជានិច្ច។
ការទុកដាក់ផ្លូវអ្នកនឹងព្រះអម្ចាស់គឺជាសកម្មភាពតែម្តងគត់
ចំណែកឯការទុកចិត្ត គឺជាឥរិយាបថដែលធ្វើជាប់ជានិច្ច។

ម្សិលមិញនៅពេលដែលអ្នកបានដាក់លុយរបស់អ្នកនៅក្នុងធនាគារួច
ហើយ អ្នកមិនមានការបារម្ភថាតើវានៅទីនោះ
ឬថាតើធនាគារដឹងថាត្រូវធ្វើដូចម្តេចជាមួយនឹងលុយនោះទេ
គឺអ្នកគ្រាន់តែទុកចិត្តដល់ធនាគារប៉ុណ្ណោះ។ នៅក្នុងករណីនេះ
អ្នកមិនមែនកំពុងទុកចិត្តលើធនាគារទេ
គឺអ្នកកំពុងទុកចិត្តលើព្រះអម្ចាស់វិញ
ហើយនៅពេលអ្នកឈានធ្វើជំហានទាំងពីរដំបូង
ជំហានទីបីគឺជារបស់ព្រះអម្ចាស់ ព្រះអង្គនឹងធ្វើវា
ព្រះអង្គនឹងធ្វើឲ្យវាសម្រេចចេញជារូបរាងឡើង។

ស្ថានភាពអ្វីក៏ដោយដែលអ្នកមាននៅក្នុងគំនិត តម្រូវការអ្វីក៏ដោយ
បញ្ហាអ្វីក៏ដោយ ការសម្រេចចិត្តអ្វីក៏ដោយ
អ្នកត្រូវតែទុកដាក់វានឹងព្រះអម្ចាស់ នេះគឺជាសកម្មភាព។
អ្នកបន្តធ្វើការទុកចិត្តលើព្រះអម្ចាស់ជានិច្ច នេះហើយគឺជាឥរិយាបថ។
អ្នកមានការធានាដ៏សុខសាន្ត និងដ៏អស្ចារ្យនោះ។ ព្រះអម្ចាស់នឹងធ្វើវា

វាស្ថិតនៅក្នុងការគ្រប់គ្រងរបស់ទ្រង់។
អ្នកអាចទុកចិត្តធនាគារជាមួយនឹងលុយរបស់អ្នកបាន
ហើយអ្នកក៏អាចទុកចិត្តលើព្រះអម្ចាស់ជាមួយនឹងបញ្ហារបស់អ្នកបាន
ដែរ។ ចូរគ្រាន់តែថ្វាយវាទៅទ្រង់ ទុកដាក់វានឹងទ្រង់
និងបន្តទុកចិត្តនៅលើទ្រង់ជានិច្ច។

: WD-WFTW-002-KHM
: 24 Feb 2026
: derekprince.com/km/resources

